# ៦. ការដាំបញ្ចូលទៅក្នុងតំបន់ដែលឋិតក្នុងដំណាក់កាលតំបូងនៃការកកើតទៅជាព្រៃធម្មតាឡើងវិញ

## ៦.១ យុត្តិកម្ម

ដំណើរវិវឌ្ឍន៍ដោយធម្មជាតិនៃព្រៃឈើពីព្រៃរេចរិលទៅរកសភាពដើមនៃព្រៃដែលពេញរូបរាងឡើងវិញគឺជាដំណាក់កាលមួយប្រកបដោយសក្តានុពលក្នុងការសំរេចឱ្យបាននូវប្រភពធនធានព្រៃឈើអចិន្ត្រៃយ៍មួយប្រកបដោយតំលៃសេដ្ឋកិច្ចដ៏ធំធេង។ គុណសម្បត្តិនៃការប្រើប្រាស់ព្រៃរេចរិលដែលមានស្រាប់ គឺការចំណាយក្នុងការរៀបចំនិងគ្រប់គ្រងព្រៃ ឈើតិចជាងយ៉ាងច្រើនបើធៀបនឹងការកាប់សំអាតព្រៃហើយដាំឈើឡើងវិញ។ ការរក្សាដំណុះព្រៃរេចរិលធានាផងដែរនូវសេវាកម្មអេកូឡូស៊ី និងរក្សានូវផលិតផលនានាសំរាប់តំរូវការសង្គម។

ព្រៃរេចរិលដែលឋិតក្នុងដំណាក់កាលតំបូងនៃការកកើតទៅជាព្រៃធម្មតាឡើងវិញ មានលក្ខណៈសម្បត្តិដូចខាងក្រោម:

- ដើមឈើដុះជាជ្រុំៗ ក្នុងកំរិតដង់ស៊ីតេខុសៗគ្នា និងមានប្រភពផ្សេងៗគ្នា (ខ្លះដុះចេញពីគ្រាប់ ខ្លះដុះចេញពីឫស និង ពីគល់ចាស់) ហើយជាទូទៅដើមឈើមានកំពស់មិនលើសពី ៣ ម។
- នៅក្នុងដំណុះព្រៃរេចរិលនេះ គេជួបប្រទះនូវទីវាលតូចៗដែលពុំទាន់មានដុះដើមឈើ។
- មីក្រូអាកាសធាតុនៃព្រៃឈើ មិនទាន់មាននៅឡើយទេ។

## ៦.២ ការអនុវត្តន៍

- ការពារដំណុះព្រៃរេចរិលនោះឱ្យជៀសផុតពីការបំផ្លាញជាទ្រង់ទ្រាយធំជាបន្តទៀត (ដូចជាការកាប់ឈើ ការស្មោះសំបកនិងកាប់មែកឈើ ការគាស់រានដីធ្វើដំណាំកសិកម្ម ការព្រលែងសត្វ និង ភ្លើងឆេះព្រៃ)។ ដើម្បីអនុញ្ញាតឱ្យមានការបន្តពូជដោយធម្មជាតិ ហើយបង្កើតរចនាសម្ព័ន្ធព្រៃធម្មតាឡើងវិញ។
- ដាំបញ្ចូលនូវប្រភេទ ឈើដែលមានតំលៃពាណិជ្ជកម្ម ឬមានតំលៃខាងសង្គម។ ការងារនេះធ្វើឡើងតាមរយៈការដាំកូនឈើជាជ្រុំៗ ក្នុងគំលាត ២ម x ២ម នៅកន្លែងដែលមានប្រលោះព្រៃបើកចំហគ្រប់គ្រាន។
- ប្រភេទឈើភាគច្រើន ពពួកគុម្ពព្រឹក្ស ឫស្សី ។ល។ ដែលផ្តល់ផលិតផល ក្រៅពីឈើ (សូមមើលតារាងទី ២ នៃឧបសម្ព័ន្ធទី ១០) ហើយអាចបំពេញតំរូវការនៃប្រជាជនមូលដ្ឋាន សុទ្ធតែមានអាទិភាពសំរាប់ការប្រើប្រាស់ក្នុងការស្តារដីព្រៃរេចរិលឡើងវិញ។

***សូមប្រើប្រាស់ទំព័របន្ថែម និង ឧបសម្ព័ន្ធនានាដូចខាងក្រោម:***

ឧបសម្ព័ន្ធទី ១: ការជ្រើសរើសប្រភេទឈើ

ឧបសម្ព័ន្ធទី ២: លទ្ធកម្មគ្រាប់ពូជ

ឧបសម្ព័ន្ធទី ៣: ការងារនៅថ្នាលបណ្ដុះកូនឈើ

ឧបសម្ព័ន្ធទី ៤: ការងារនៅចំការដាំឈើ

ឧបសម្ព័ន្ធទី ៥: ការថែរក្សាចំការឈើដាំ

ឧបសម្ព័ន្ធទី ៨: វិធីសាស្ត្រក្នុងការជ្រើសរើសប្រភេទឈើសំរាប់ដាំដើម្បីកាត់បន្ថយភាពក្រីក្រ

ឧបសម្ព័ន្ធទី ១០: ប្រភេទឈើមួយចំនួនដែលផ្ដល់ផលិតផលបន្ថែមក្រៅពីឈើ

ទំព័របន្ថែមទី១: ការគណនាតំរូវការគ្រាប់ពូជឈើ

# ៧. ការដាំឈើជាចំការតូចៗដោយកសិករ

## ៧.១ យុត្តិកម្ម

ភាពខ្សត់ខ្សោយនៃធនធានព្រៃឈើនៅក្នុងមូលដ្ឋាន បានផ្ដល់ឱកាសឱ្យកសិករិរិះរកប្រាក់ចំណូលបន្ថែមទៀត តាមរយៈការងារដាំឈើ។ នៅក្នុងតំបន់ខ្លះនៃប្រទេសកម្ពុជា ដូចជាខេត្តកំពង់ឆ្នាំង និងតាកែវ កសិករចាប់ផ្ដើមការងារដាំឈើនៅលើដីកម្មសិទ្ធិរបស់ខ្លួនដោយគ្មានឬមានជំនួយតិចតួចប៉ុណ្ណោះពីអ្នកផ្ដល់ជំនួយនានា។ ការងារដែលចាប់ផ្ដើមដោយកសិករនេះអាចសំរេចបានជោគជ័យដោយសារមូលហេតុពីរយ៉ាងគឺៈ ទីមួយ ដោយសារកសិករមានធនធានថវិកាតិចតួច ដូច្នេះរាល់ដើមឈើដែលបានដាំតំណាងឱ្យការយល់ដឹងក្នុងការធ្វើវិនិយោគ ព្រោះថាគាត់អាចមានជំរើសក្នុងការប្រើប្រាស់ដីផ្សេងៗទៀត។ ទីពីរ កសិករដាំដើមឈើតែក្នុងបរិមាណមួយដែលអាចថែរក្សាបានដោយគត់មត់។ ហេតុផលដែលនាំឱ្យកសិករតូចតាចចូលរួមក្នុងការងារដាំឈើគឺ ដោយសារគាត់មានចំណាប់អារម្មណ៍ក្នុងការពង្រឹងជីវភាពគ្រួសារតាមរយៈការបង្កើតផលិតផលឈើសំរាប់ប្រើប្រាស់ក្នុងគ្រួសារនិងសំរាប់លក់ដូរ។

## ៧.២. ការអនុវត្តន៍

កសិករម្នាក់ឬមួយក្រុមអាចបង្កើតចំការឈើដែលផ្ដល់ផលច្រើនប្រភេទ ដូចជាឈើសំណង់ សរសរ អុស ចំណីសត្វ និងផលិតផលមិនមែនឈើជាច្រើនប្រភេទទៀតសំរាប់ការប្រើប្រាស់ក្នុងគ្រួសារនិងសំរាប់លក់ដូរ។ ចំការឈើក៏អាចជួយការពារបរិស្ថានចំការដំណាំដោយបង្កើនគុណភាពដី ការពារការហូរច្រោះ ផ្ដល់ម្លប់ដល់មនុស្សនិងសត្វក៏ដូចជាបង្កើនគុណភាពបរិស្ថានទូទៅផងដែរ។

សូមមើលឧបសម្ព័ន្ធទី ៩ សំរាប់ដំណើរការជ្រើសរើសប្រភេទឈើឱ្យបានសមស្រប និងតារាងទី២ នៃឧបសម្ព័ន្ធទី ១១ សំរាប់ឧទាហរណ៍នៃប្រភេទឈើដែលផ្ដល់ផលិតផលក្រៅពីឈើជាច្រើនប្រភេទ។

***សូមប្រើប្រាស់ទំព័របន្ថែម និង ឧបសម្ព័ន្ធនានាដូចខាងក្រោមៈ***

ឧបសម្ព័ន្ធទី ១: ការជ្រើសរើសប្រភេទឈើ